# ក្របខណ្ឌគ្រប់គ្រងហានិភ័យគម្រោង

## I. សេចក្តីផ្តើម

ការគ្រប់គ្រងហានិភ័យគម្រោង គឺជាដំណើរការនៃការកំណត់និងវិភាគហានិភ័យនានាដែលអាចកើតឡើងក្នុងកំឡុងពេលវដ្តនៃគម្រោង ដើម្បីចាត់វិធានការក្នុងការកាត់បន្ថយឬទប់ស្កាត់នូវផលប៉ះពាល់ពីហានិភ័យទាំងនោះឲ្យបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព។ ដើម្បីជាគន្លឹះក្នុងការគ្រប់គ្រងហានិភ័យគម្រោង និងដើម្បីក្លាយជាស្ថាប័នទទួលថវិកាផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង លេខាធិការដ្ឋាន គ.ជ.អ.ប. បានតាក់តែងនិងដាក់ចេញនូវនីតិវិធីសម្រាប់ការគ្រប់គ្រងហានិភ័យគម្រោងដែលផ្តោតលើ៖

- ក្របខណ្ឌការគ្រប់គ្រងហានិភ័យគម្រោង ត្រូវបានរៀបចំឡើងដោយផ្អែកតាមសៀវភៅណែនាំស្តីពីគោលការណ៍និយាមប្រតិបត្តិការសម្រាប់គម្រោងជំនួយពីក្រៅប្រទេស (SOP)
- ការវិភាគហានិភ័យ និងវិធានការនៃការកាត់បន្ថយផលប៉ះពាល់ហានិភ័យ នៅក្នុងក្របខណ្ឌផ.អ.៣ ដំណាក់កាលទី៣
- នីតិវិធីនៃការគ្រប់គ្រងនិងវិភាគហានិភ័យគម្រោងដាច់ដោយឡែកនានា ដែលបានពិភាក្សា និងឯកភាពជាមួយនឹងដៃគូអភិវឌ្ឍន៍។

ការគ្រប់គ្រងហានិភ័យគម្រោងទាំងនេះ នឹងទទួលខុសត្រូវអនុវត្តដោយអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋានគ.ជ.អ.ប. ដោយមានការិយាល័យគ្រប់គ្រងគម្រោងជាសេនាធិការ។

## II. ការកំណត់ក្របខណ្ឌគ្រប់គ្រងហានិភ័យ

លេខាធិការដ្ឋានគ.ជ.អ.ប. នឹងរៀបចំអនុម័តនូវក្របខណ្ឌការគ្រប់គ្រងហានិភ័យសម្រាប់គម្រោងដែលផ្តល់មូលនិធិដោយមូលនិធិអាកាសធាតុបៃតង និងគម្រោងផ្សេងៗទៀត ក្នុងក្របខណ្ឌផែនការសកម្មភាពនិងថវិការបស់គ.ជ.អ.ប. ដែលមិនទាន់មានគោលការណ៍ច្បាស់លាស់ក្នុងការអនុវត្តក្របខណ្ឌការគ្រប់គ្រងហានិភ័យនៅឡើយ។ ក្របខណ្ឌការគ្រប់គ្រងហានិភ័យ មានសង្គតិភាពនឹងសៀវភៅណែនាំស្តីពីនីតិវិធីនិយាមប្រតិបត្តិការស្ថិតនៅក្នុងផ្នែកទី១០ ដែលបានចែងអំពីហានិភ័យគម្រោងនិងវិធានការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យ។ ក្របខណ្ឌការគ្រប់គ្រងហានិភ័យរួមបញ្ចូលនូវមុខងារគ្រប់គ្រងគម្រោង ដែលមានហានិភ័យជាលក្ខណៈឯករាជ្យ (independent project-at-risk function)។

ក្របខណ្ឌការគ្រប់គ្រងហានិភ័យ នឹងមានភាពបត់បែនខ្លះ ដើម្បីធានាថានីតិវិធីគ្រប់គ្រងមានភាពសមស្របនឹងទំហំនៃគម្រោង។ ជាទូទៅ វិធានវាស់វែងហានិភ័យមានលក្ខណៈស្តង់ដា ត្រូវអនុវត្តសម្រាប់សកម្មភាពគម្រោងដែលទទួលបានមូលនិធិគាំទ្រក្នុងលក្ខណៈជាគម្រោងតូចៗ (ថវិកាក្រោម២៥០.០០០ដុល្លារ) ខណៈដែលវិធានវិភាគដាក់លាក់ដាច់ដោយឡែកផ្សេងទៀត នឹងយកមកអនុវត្តសម្រាប់គម្រោងមូលនិធិគាំទ្រក្នុងលក្ខណៈជាគម្រោងធំៗ។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ លេខាធិការដ្ឋានគ.ជ.អ.ប. នឹងរៀបចំប្រព័ន្ធទិន្នន័យនៃការគ្រប់គ្រងហានិភ័យមួយ ដោយមានការសហការរវាងអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន និងអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី។ ប្រព័ន្ធនេះ នឹងជួយក្នុងការផ្តល់ជារបាយការណ៍ ដែលបង្ហាញអំពីប្រសិទ្ធិភាពនៃការអនុវត្តមុខងារគម្រោងដែលមានហានិភ័យ និងប្រើប្រាស់សម្រាប់ការធ្វើសវនកម្មតាមការចាំបាច់ ។

## III. ម៉ាទ្រិចការវិភាគហានិភ័យ

គម្រោងទាំងអស់នឹងមានតារាងម៉ាទ្រិចការវិភាគហានិភ័យ ដែលនឹងត្រូវរៀបចំតាក់តែងមុនពេលចាប់ផ្តើមអនុវត្តគម្រោង។ តារាងម៉ាទ្រិចការវិភាគហានិភ័យ នឹងបង្ហាញដូចខាងក្រោម៖

- **ការចាត់ថ្នាក់៖** ការចាត់ថ្នាក់ហានិភ័យដែលមានលក្ខណៈសាមញ្ញ ដូចជា ១) ហានិភ័យនៃការអនុវត្ត ២) ហានិភ័យនៃភាពទុកចិត្ត ៣) ហានិភ័យនៃបរិស្ថាន និងកិច្ចសុវត្ថិភាពសង្គម ៤) ហានិភ័យនៃនិរន្តរភាព
- **ផលប៉ះពាល់៖** ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ជាអវិជ្ជមាននឹងកើតមាន ប្រសិនបើហានិភ័យនោះកើតមានឡើងនៅកម្រិតខ្ពស់ មធ្យម និងទាប
- **ភាពដែលអាចកើតមាននូវ**ព្រឹត្តិការណ៍ហានិភ័យកម្រិតខ្ពស់ មធ្យម ឬទាប
- **វិធានការនៃការកាត់បន្ថយផលប៉ះពាល់៖** ការរៀបចំគម្រោង ដែលកាត់បន្ថយភាពអាចកើតមាននូវហានិភ័យ ឬការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីហានិភ័យដែលនឹងកើតឡើង
- **ការកំណត់សូចនាករ** ដើម្បីកំណត់និងចាត់ថ្នាក់ហានិភ័យដែលមានកម្រិតពណ៌ក្រហម ឬ លឿង
- **ស្ថានភាពបច្ចុប្បន្នភាព៖** ការបញ្ចូលព័ត៌មានអំពីស្ថានភាពបច្ចុប្បន្នភាពក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ដែលរាប់បញ្ចូលកាលបរិច្ឆេទ ស្ថានភាពហានិភ័យ "ក្រហម" ឬ "លឿង" ឬ "បៃតង" និងការផ្តល់មតិយោបល់នានា ។

តារាងម៉ាទ្រិចការវិភាគហានិភ័យរួមបញ្ចូលនូវសូចនាករគោលនៃហានិភ័យគម្រោង ចំនួន០៩ សម្រាប់ធ្វើការត្រួតពិនិត្យគម្រោងទាំងអស់។ សូចនាករនោះមានដូចខាងក្រោម៖

| សូចនាករហានិភ័យគម្រោង | ក្រហម | លឿង |
|---|---|---|
| **យឺតយ៉ាវក្នុងការចំណាយ** | តិចជាង ៤០% ធៀបនឹងផែនការ | តិចជាង ៧០% ធៀបនឹងផែនការ |
| **ការសម្រេចបានលទ្ធផលទាប** | លទ្ធផលសម្រេចបានតិចជាង៤០%ធៀបនឹងផែនការ | លទ្ធផលសម្រេចបានតិចជាង៧០% ធៀបនឹងផែនការ |
| **គុណភាពលទ្ធផលទាប** | លទ្ធផលសម្រេចបានមិនមានប្រសិទ្ធភាព ឬមិនសមស្របនឹងគោលបំណង | គុណភាពនៃលទ្ធផលសម្រេចបានមានកម្រិតទាបខ្លាំងដែលបានកាត់បន្ថយយ៉ាងខ្លាំងនៃផលប៉ះពាល់ជាវិជ្ជមាននៃគម្រោង |
| **ការបញ្ជ្រាបយេនឌ័រ** | រំលោភធ្ងន់ធ្ងរទៅនឹងគោលនយោបាយយេនឌ័រ | ផែនការបញ្ជ្រាបយេនឌ័រមិនបានអនុវត្តឬមិនបានចងក្រងជាឯកសារ |

| | | |
|---|---|---|
| **សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុខ្សោយ** | នីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុបានរកឃើញថា មានភាពមិនត្រឹមត្រូវ | របាយការណ៍ហិរញ្ញវត្ថុមិនបានបញ្ជប់ឬយឺតយ៉ាវក្នុងរយៈពេល៣ខែ |
| **ការតវ៉ាពីអ្នកពាក់ព័ន្ធ** | អ្នកតវ៉ាច្រើនលើសពីមួយបានដាក់បណ្តឹងមកលេខាធិការដ្ឋានគ.ជ.អ.ប. ហើយបញ្ហាមិនបានដោះស្រាយក្នុងរយៈពេល៣ខែ | អ្នកតវ៉ាម្នាក់បានដាក់បណ្តឹងមកលេខាធិការដ្ឋានគ.ជ.អ.ប. ហើយមិនបានដោះស្រាយក្នុងអំឡុងពេល៣ខែ ឬ អ្នកតវ៉ាលើសពីមួយ បានដាក់បណ្តឹង មកលេខាធិការដ្ឋាន គ.ជ.អ.ប |
| **សមត្ថភាពលទ្ធកម្មខ្សោយ** | រកឃើញកំហុសឆ្គងធំៗក្នុងការអនុវត្តនីតិវិធីលទ្ធកម្ម | ឯកសារបង្ហាញភាពត្រឹមត្រូវនៃការអនុវត្តនីតិវិធីលទ្ធកម្មសម្រាប់អធិការកិច្ច មិនអាចរកបាន |
| **កិច្ចសុវត្ថិភាពបរិស្ថាននិងសង្គម** | មានកំហុសឆ្គងធ្ងន់ធ្ងរលើការអនុវត្តកិច្ចសុវត្ថិភាពបរិស្ថាននិងសង្គម ត្រូវបានរកឃើញ | ការអនុវត្តនីតិវិធីកិច្ចសុវត្ថិភាពបរិស្ថាន និងសង្គម មិនបានចងក្រងជាឯកសារត្រឹមត្រូវ |
| **និរន្តរភាព** | មានការផ្លាស់ប្តូរឬមានព្រឹត្តិការណ៍ផ្សេងៗដែលធ្វើឲ្យផលប្រយោជន៍គម្រោងមិនមាននិរន្តរភាព | ផ្នែកខ្លះនៃការរៀបចំគម្រោងសម្រាប់ធាននានិរន្តរភាព មិនត្រូវបានអនុវត្ត |

ចំពោះគម្រោងមានថវិកាក្រោម ២៥០.០០០ដុល្លារ ដែលជាជំនួយ ការប្រើប្រាស់សូចនាករហានិភ័យគម្រោងខាងលើនេះមានលក្ខណៈសមស្របក្នុងការអនុវត្ត។ ដោយឡែក គម្រោងដែលមានថវិកាលើសពី ២៥០.០០០ដុល្លារ ហានិភ័យនឹងត្រូវវិភាគ ដែលជាផ្នែកមួយនៃការរៀបចំគម្រោង ហើយហានិភ័យដែលបានរកឃើញនឹងត្រូវបញ្ចូលទៅក្នុងតារាងម៉ាទ្រិចការវិភាគហានិភ័យខាងលើ ។

តារាងម៉ាទ្រិចការវិភាគហានិភ័យ នឹងរួមបញ្ចូលវិធានការនៃការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យនានាដូចជា ១) ផលប៉ះពាល់ហានិភ័យកម្រិតខ្ពស់ឬមធ្យម និង ២) ភាពអាចកើតមានហានិភ័យកម្រិតខ្ពស់ឬមធ្យម។

ចំពោះហានិភ័យទាំងអស់ដែលមានផលប៉ះពាល់កម្រិតខ្ពស់ និងភាពអាចកើតមាននូវហានិភ័យកម្រិតខ្ពស់ឬមធ្យមនោះ ក្របខណ្ឌការគ្រប់គ្រងហានិភ័យ នឹងបង្ហាញសូចនាករហានិភ័យ សម្រាប់ត្រួតពិនិត្យ និងប្រើប្រាស់ក្នុងការចាត់ថ្នាក់ហានិភ័យដែលស្ថិតនៅកម្រិតស្ថានភាព "ក្រហម" ឬ "លឿងៗ ឬ "បៃតង" ។

ជាទូទៅ សូចនាករហានិភ័យមិនគួរមានច្រើនជាង៦ ដើម្បីត្រួតពិនិត្យនិងតាមដានគម្រោងនីមួយៗ ប្រសិនបើមានសូចនាករហានិភ័យច្រើនពេកដែលទាមទារនូវការត្រួតពិនិត្យ នោះគម្រោងគួររៀបចំសារឡើងវិញ ដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។

ក្របខណ្ឌការគ្រប់គ្រងហានិភ័យ នឹងត្រូវបានរៀបចំដោយអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី ដែលជាផ្នែកមួយនៃដំណើរការរៀបចំគម្រោង។ ក្របខណ្ឌការគ្រប់គ្រងហានិភ័យគម្រោង នឹងត្រូវបានពិនិត្យឡើងវិញដោយមន្ត្រី

នៃអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានដែលបានទទួលវគ្គបណ្តុះបណ្តាលជំនាញក្នុងការ អនុវត្តមុខងារនេះ។ ក្របខណ្ឌការគ្រប់គ្រងហានិភ័យគម្រោងចុងក្រោយ នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យ (អាចជា Microsoft Excel Workbook) ស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន។

## IV. ការតាមដានត្រួតពិនិត្យ

អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី មានភារកិច្ចទទួលខុសត្រូវធ្វើរបាយការណ៍ស្របតាមសូចនាករហានិភ័យគម្រោងដែលមានរយៈពេលយ៉ាងច្រើនត្រឹម៦ខែ។ អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី នឹងរាយការណ៍តាមទម្រង់កំណត់មួយជូនទៅអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន។

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន នឹងចាត់ថ្នាក់គម្រោងដែលមានហានិភ័យ ក្នុងករណី៖

- ស្ថានភាពហានិភ័យកម្រិតខ្ពស់ណាមួយមានពណ៌"ក្រហម"
- ស្ថានភាពហានិភ័យកម្រិតមធ្យមមានចំនួន៣ មានពណ៌"ក្រហម"
- ស្ថានភាពហានិភ័យមានកម្រិតមធ្យមយ៉ាងតិចចំនួន១ មានពណ៌"ក្រហម" និងស្ថានភាពហានិភ័យកម្រិតខ្ពស់យ៉ាងតិច១ ឬស្ថានភាពហានិភ័យកម្រិតមធ្យមចំនួន៣ មានពណ៌"លឿង"

សូចនាករទូទៅនៃគម្រោងដែលមានហានិភ័យអាចចាត់ទុកថាមានលក្ខណៈដូចគ្នានឹងហានិភ័យកម្រិតខ្ពស់។

## V. វិធានការអនុវត្តក្នុងករណីគម្រោងមានហានិភ័យ

ក្នុងករណីគម្រោងត្រូវបានចាត់ថ្នាក់ថាមានហានិភ័យ៖

- អង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុនឹងត្រូវបានផ្តល់ព័ត៌មាន ហើយថវិកានឹងមិនត្រូវបន្តផ្តល់ជូនស្ថាប័ន អនុវត្តគម្រោងដែលមានហានិភ័យនោះទេរហូតដល់មានការព្រមព្រៀង និងអនុវត្តសកម្មភាពកែសម្រួលបញ្ហា។
- ប្រសិនបើគម្រោងមួយណាស្ថិតក្នុងស្ថានភាពគម្រោងមានហានិភ័យក្នុងរយៈពេលមួយឆ្នាំ គម្រោងនោះនឹងត្រូវលុបចោល ហើយលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងមានវិធានការដកថវិកាដែលនៅសល់ពីស្ថាប័នអនុវត្តនោះមកវិញ ។

## VI. វិធានការកែសម្រួល

ក្នុងករណីគម្រោងចាប់ផ្តើមស្ថិតក្នុងស្ថានភាពមានហានិភ័យ អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធីនឹងអន្តរាគមន៍ឲ្យបានទាន់ពេលដោយ៖

- ជូនដំណឹងដល់ស្ថាប័នអនុវត្តគម្រោងថា គម្រោងដែលអនុវត្តស្ថិតនៅក្នុងហានិភ័យ
- ពិភាក្សា និងឯកភាពជាមួយស្ថាប័នអនុវត្តនូវផែនការសកម្មភាពជាមួយនឹងក្របខណ្ឌពេលវេលាជាក់លាក់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនានា

- ឯកភាពលើលក្ខខណ្ឌនានា ដើម្បីចាកចេញពីស្ថានភាពគម្រោងមានហានិភ័យ
- ជូនដំណឹងដល់អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននូវផែនការនិងលក្ខខណ្ឌដែលបានឯកភាព
- ត្រួតពិនិត្យជារៀងរាល់ខែ ដើម្បីបញ្ជាក់ថាវិធានការដែលបានឯកភាពនោះ ត្រូវបានអនុវត្ត
- ប្រសិនបើអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី ពិនិត្យឃើញថាគ្មានលទ្ធភាពជាក់លាក់ដែលគម្រោងនោះអាចរួចផុតពីស្ថានភាពគម្រោងមានហានិភ័យ នោះអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធីនឹងផ្តល់ដំណឹងដល់អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំលេខាធិការដ្ឋានគ.ជ.អ.ប. ដើម្បីស្នើសុំគោលការណ៍លុបគម្រោង និងបង្វែរថវិកាដែលនៅសល់មកវិញ។

ថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៩

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

លេខាធិការដ្ឋាន

**ខៀវ ចំរើន**

## តារាងម៉ាទ្រិចការវិភាគហានិភ័យគម្រោងរបស់លេខាធិការដ្ឋានគ.ជ.អ.ប.

| ហានិភ័យ ឬសូចនាករទូទៅនៃគម្រោងមានហានិភ័យ | ផលប៉ះពាល់ | លទ្ធភាព | វិធានការកាត់បន្ថយ | កម្រិត | | ស្ថានភាពបានធ្វើបច្ចុប្បន្នភាព | |
|---|---|---|---|---|---|---|---|
| | | | | ក្រហម | លឿង | កាលបរិច្ឆេទ | ស្ថានភាព/យោបល់ |
| **១. ការអនុវត្ត** | | | | | | | |
| ទូទៅ: យឺតក្នុងការចំណាយ | ខ្ពស់ | | | < ៤0% នៃផែនការ | < ៧0% នៃផែនការ | | |
| ទូទៅ: សម្រេចលទ្ធផលយឺត | ខ្ពស់ | | | < ៤0% នៃផែនការ | < ៧0% នៃផែនការ | | |
| ទូទៅ: គុណភាពលទ្ធផលទាប | ខ្ពស់ | | | លទ្ធផលមិនស្របនឹងគោលបំណងចង់បាន | គុណភាពទាបនឹងបន្ថយផលប៉ះពាល់ | | |
| ទូទៅ: ការបញ្ជ្រាបយេនឌ័រ | ខ្ពស់ | | | រំលោភធ្ងន់ធ្ងរនឹងគោលនយោបាយការបញ្ជ្រាបយេនឌ័រ | ផែនការការបញ្ជ្រាបយេនឌ័រមិនបានអនុវត្ត ឬចងក្រងជាឯកសារ | | |
| ទូទៅ: ការតវ៉ារបស់អ្នកពាក់ព័ន្ធ | ខ្ពស់ | | | មានការតវ៉ាលើសពីមួយ និងមិនបានដោះស្រាយក្រោយពីរយៈពេល៣ខែ | ការតវ៉ាមួយ មិនបានដោះស្រាយក្រោយពីរយៈពេល៣ខែ ឬមានការតវ៉ាលើសពីមួយ | | |
| | | | | | | | |
| **២. សេចក្តីទុកចិត្ត** | | | | | | | |
| ទូទៅ: សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុខ្សោយ | ខ្ពស់ | | | រំលោភធ្ងន់ធ្ងរទៅនឹងគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ | របាយការណ៍ហិរញ្ញវត្ថុមិនបាន | | |

| ហានិភ័យ ឬសូចនាករទូទៅនៃគម្រោងមានហានិភ័យ | ផលប៉ះពាល់ | លទ្ធភាព | វិធានការកាត់បន្ថយ | កម្រិត | | ស្ថានភាពបានធ្វើបច្ចុប្បន្នភាព | |
|---|---|---|---|---|---|---|---|
| | | | | ក្រហម | លឿង | កាលបរិច្ឆេទ | ស្ថានភាព/យោបល់ |
| | | | | | បញ្ជាប់ត្រឹមត្រូវ ឬ យឺតយ៉ាវ ៣ខែ | | |
| រូមៈសមត្ថភាពលទ្ធកម្មខ្សោយ | ខ្ពស់ | | | រកឃើញកំហុសឆ្គងធំៗក្នុងការអនុវត្តគោលការណ៍លទ្ធកម្ម | ឯកសារលទ្ធកម្មមិនមានគ្រប់គ្រាន់ ឬមិនអាចរកបាន | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| **៣. កិច្ចសុវត្ថិភាពបរិស្ថាន និងសង្គម** | | | | | | | |
| ទូទៅៈ គោលនយោបាយកិច្ចសុវត្ថិភាពបរិស្ថាន និងសង្គមមិនបានអនុវត្ត | ខ្ពស់ | | | រំលោភយ៉ាងធ្ងន់ធ្ងរទៅនឹងគោលនយោបាយកិច្ចសុវត្ថិភាពបរិស្ថាន និងសង្គម | នីតិវិធីកិច្ចសុវត្ថិភាពបរិស្ថាន និងសង្គម មិនបានចងក្រងជាឯកសារត្រឹមត្រូវ | | |
| | | | | | | | |
| | | | | | | | |
| **៤. និរន្តរភាព** | | | | | | | |
| ទូទៅៈ ផលប្រយោជន៍គម្រោងមិនមាននិរន្តរភាព | ខ្ពស់ | | | មានការផ្លាស់ប្តូរ ឬ មានព្រឹត្តិការណ៍ដែលធ្វើឲ្យផលប្រយោជន៍គម្រោងមិនមាននិរន្តរភាព | វិធានការដើម្បីធានានូវនិរន្តរភាពមិនបានអនុវត្ត | | |
| | | | | | | | |
| | | | | | | | |